RAC Ratings

របាយការណ៍វាយតម្លៃទ្នកាពសង
លេខ: ០០៥/២៣
ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣

ក្រុមហ៊ុន តែលក្វថេក

ចំណាត់ថ្នាក់ឥណទាន		ព័ត៌មានសញ្ញាបណ្ណ	
ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន	**KhB**	ទំហំ	២០ លានដុល្លាអាមេរិក
ការវាយតម្លៃ	**អវិជ្ជមាន**	ចំនួននៃការទូទាត់	ប្រចាំឆមាស
ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ	**khAAA**	រយៈពេលឥណប្រតិទាន	៥ឆ្នាំ (មិនមានការទូទាត់ប្រាក់ដើមរយៈពេល១.៥ឆ្នាំ)
		ប្រភេទ	មិនមានទ្រព្យតម្កល់ ប៉ុន្តែមានបុគ្គលធានា
		អត្រាគូប៉ុង	SOFR + ២.៥% ក្នុងមួយឆ្នាំ
		បុគ្គលធានា	Credit Guarantee & Investment Facility (CGIF)

អ្នកវាយតម្លៃ៖

លោក ស៊ីសុវត្តិ ចក្រការា CFA
s.chakara@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៩៨ ៧៧៧

កញ្ញា សៀង ដារីយ៉ា
s.darya@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៨៦ ៧៧៧

កញ្ញា ពៅ ស៊ុនវណ្ណដែត
p.sunvandeth@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣១៨ ៧៧៧

កញ្ញា លឹម អច្ឆរាទេពី
l.achhakratepy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ២៥០ ៧៧៧

អ្នកស្រី សុង ហេងជូលី
hengjulie.song@3e-fii.com
(+៨៥៥) ៨៩ ២៣៩ ២៤៩

លោក ញាន តុលា
tola.nhean@3e-fii.com

ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ

ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណនេះត្រូវបានវាយតម្លៃដោយយោងតាមចរិតលក្ខណៈនៃសញ្ញាបណ្ណដូចដែលបានរៀបរាប់នៅក្នុងរបាយការណ៍នេះដែលយោងទៅតាមកិច្ចសន្យាធានា និងឯកសារពាក់ព័ន្ធផ្សេងទៀតដែលបានផ្តល់អោយយើងនៅពេលនេះ ទាំងក្នុងសេចក្តីព្រាង ឬក្នុងទម្រង់ចម្លង។ ការវាយតម្លៃនេះមានប្រសិទ្ធភាពតែនៅពេលដែល មូលបត្របំណុលត្រូវបានបោះផ្សាយ (ការធានាមានសុពលភាពតែនៅពេលដែលមូលបត្របំណុលត្រូវបានបោះផ្សាយ)។ ការវាយតម្លៃនឹងត្រូវបានព្យួរ ឬដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ឬលុបចោលប្រសិនបើមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ណាមួយពីកិច្ចសន្យាធានា។

យើងផ្តើមការវាយតម្លៃទ្នភាពសងរបស់ក្រុមហ៊ុន តែលកូថេក ដោយការផ្តល់ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ (BCR) khAAA (ចំណាត់ថ្នាក់ជាតិ) ដែលនៅក្នុងបរិបទកម្ពុជាបង្ហាញនូវ «សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ»។ នៅក្នុងវិធីសាស្ត្ររបស់យើង BCR ត្រូវបានវិភាគដោយផ្អែកលើសមាសភាគចំនួនពីរគឺ៖ ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន (ICR) និង ពិន្ទុស្តារឡើងវិញ (RS)។

ពិន្ទុស្តារឡើងវិញស្មើនឹង (RS) «ហានិភ័យទាបណាស់»។ មូលបត្របំណុលគឺត្រូវបានធានាសងដែលមិនអាចដកហូតវិញបាន និងដោយគ្មានលក្ខខណ្ឌចំពោះការខកខានទូទាត់ការប្រាក់ ឬប្រាក់ដើមជាមួយទំហំនៃការធានាសរុបគឺ ១០០% ទៅលើទាំងប្រាក់ដើម និងការប្រាក់ដោយក្រុមហ៊ុន CGIF ដែលជាស្ថាប័នទទួលបាន ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន AA (សកល) ដោយ S&P និង AAA (ជាតិ) ដោយ RAM Ratings (ម៉ាឡេស៊ី) TRIS (ថៃ) Fitch Ratings Indonesia និង Pefindo CRA (ឥណ្ឌូនេស៊ី)។ អាស្រ័យហេតុនេះ យើងផ្តល់ចំណាត់ថ្នាក់នៃ khAAA លើមាត្រដ្ឋានជាតិរបស់យើង ចំពោះសម្រាប់ការវាយតម្លៃឥណទានសញ្ញាបណ្ណ។

តាមទស្សនៈរបស់យើង កិច្ចព្រមព្រៀងធានាបង្ហាញអំពីភាពត្រឹមត្រូវនៃការជំនួសឥណទានពី ICR នៃ ក្រុមហ៊ុន តែលកូថេក ដោយ ICR នៃ CGIF។ ក្នុងករណីមានការខកខានសងបំណុល ម្ចាស់បំណុលត្រូវបានការពារដោយការធានាដែលមិនអាចដកហូតវិញបាន និងដោយគ្មានលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់ទាន់ពេលវេលាដោយ CGIF។

ការវាយតម្លៃចំណាត់ថ្នាក់ឥណទានក្រុមហ៊ុនផ្សំដោយសមាសភាគពីរ៖ ទម្រង់ឥណទានឯករាជ្យ (SACP) និងកត្តាគាំទ្រខាងក្រៅ (ESF)។ SACP វិភាគទម្រង់ឥណទានតាមរយៈហានិភ័យអាជីវកម្ម និងហានិភ័យហិរញ្ញវត្ថុរបស់ តែលកូថេក ។ ក្រុមហ៊ុន តែលកូថេក «សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច»។ ការវាយតម្លៃ SACP ចំណាត់ថ្នាក់ khB បង្ហាញពីទម្រង់ «ហានិភ័យមធ្យមទៅខ្ពស់» ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ (ខេមបូឌា) ម.ក ឆ្នាំ២០២៣
#២៤៦, មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកក់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
www.ratingagencyofcambodia.com.kh | (+៨៥៥)២៣ ៩០២ ៤០៨ | info@ratingagencyofcambodia.com.kh

ទស្សនវិស័យ

ទស្សនវិស័យ **អវិជ្ជមាន** និង ចំណាត់ថ្នាក់ **khB** ឆ្លុះបញ្ចាំងពីការរំពឹងទុករបស់យើងថាការបោះផ្សាយសញ្ញាបណ្ណនេះ ("the Bond") ដែលមានទំហំទឹកប្រាក់ ២០ លានដុល្លាអាមេរិក នឹងធ្វើអោយទំហំបំណុលរបស់ តែលកូថេក កាន់តែមានកម្រិតខ្ពស់។ ការប្រើប្រាស់ប្រាក់ចំណូលពីការបោះផ្សាយមូលបត្រគឺ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ អចលនទ្រព្យ (CAPEX) ពាក់ព័ន្ធនឹងការធ្វើឲ្យប្រសើរឡើងវិញនៃហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្ល៏។ ដូចនេះ យើងរំពឹងថាលំហូរសាច់ប្រាក់ទំនេរ (FOCF) របស់ក្រុមហ៊ុននឹងមានភាពតានតឹងបន្ថែមទៀត ដោយសារការកើនឡើងនៃ CAPEX នេះ។ ចំណាត់ថ្នាក់ khB នេះក៏បន្សល់ទុកនូវចន្លោះតិចតួចប៉ុណ្ណោះសម្រាប់ បំណុលហិរញ្ញវត្ថុដែលមានទំហំធំ និងការអនុវត្តខុស។ ដូច្នេះ ផ្អែកលើការព្យាករណ៍ហិរញ្ញវត្ថុនាពេលខាងមុខរបស់ក្រុមហ៊ុន យើងរំពឹងថា តែលកូថេក នឹងកាត់បន្ថយទំហំបំណុលរបស់ខ្លួន ។ ការកាត់បន្ថយទំហំបំណុលនេះ នឹងពឹងផ្អែកលើសមត្ថភាព របស់គណៈគ្រប់គ្រងក្នុងការបង្កើនចំណូលពី អតិថិជនដែលមានស្រាប់ និង អតិថិជនថ្មី តាមរយៈការធ្វើឲ្យប្រសើរឡើងវិញនៃបណ្តាញខ្សែកាប្ល៏សំខាន់របស់ខ្លួន។

លើសពីនេះទៀត សមត្ថភាពរបស់គណៈគ្រប់គ្រង ក្នុងការបង្កើតប្រតិបត្តការផ្សេងទៀត ដែលអាចបង្កើន ទំហំប្រាក់ចំណូលរបស់ក្រុមហ៊ុន EBITDA និង FOCF ក៏ជាចំណុចសំខាន់ផងដែរ។ តាមទស្សនៈរបស់យើង វប្បធម៌ក្រុមហ៊ុន និងបទពិសោធន៍គណៈគ្រប់គ្រង បានបង្ហាញពីសមត្ថភាពក្នុងការអនុវត្តយុទ្ធសាស្ត្រទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងពេលដ៏ខ្លីខាងមុខនេះ តែលកូថេក នឹងរងសម្ពាធកាន់តែខ្លាំង ពីភាតព្វកិច្ចសងបំណុល។ ដូច្នេះ RAC រំពឹងថា តែលកូថេក នឹងចាប់ផ្តើមកាត់បន្ថយកម្រិតបំណុលរបស់ខ្លួន ចាប់ពីឆ្នាំ២០២៥ តទៅ ដោយការកើនឡើង CAPEX នឹងមានកម្រិតខ្ពស់បំផុតនៅឆ្នាំ ២០២៤ និង ធ្លាក់ចុះវិញនៅឆ្នាំ ២០២៥ ។

កត្តាដែលមានឥទ្ធិពលលើបម្រែបម្រួលការវាយតម្លៃ

ដើម្បីពិចារណាលើការបង្កើនឡើងនូវចំណាត់ថ្នាក់ ICR របស់ក្រុមហ៊ុនអោយប្រសើរឡើង យើងត្រូវការតាមដាននិងពិនិត្យជាក់ស្តែង លើប្រាក់ចំណេញជាបន្តបន្ទាប់ និងការកាត់បន្ថយនូវទំហំបំណុលរបស់ ក្រុមហ៊ុន តែលកូថេក។ ក្នុងករណីដែល ប្រាក់ចំណេញមានការថយចុះ ការកើនឡើងនៃទំហំបំណុល ការបំពានលើកិច្ចព្រមព្រៀងនៃការខ្ចីប្រាក់ដែលមានស្រាប់ អាចបណ្តាលឲ្យយើងពិចារណាលើការបន្ទាបចំណាត់ថ្នាក់ ICR។

ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ យោងតាមចំណាត់ថ្នាក់ជាសកលរបស់ CGIF (AA ដោយ S&P Global Ratings) ។ ដូច្នេះ យើងអាចពិចារណាលើការបន្ទាបចំណាត់ថ្នាក់ BCR ប្រសិនបើការវាយតម្លៃជាសកលរបស់ CGIF ត្រូវបានបន្ទាបចំណាត់ថ្នាក់។

បញ្ហាដែលត្រូវត្រួតពិនិត្យ

ទំហំបណ្តុលរបស់ តែលកូថេក អភិបាលកិច្ចសាជីវកម្ម ប្រតិបត្តិការពិសេស (One-off transactions) និង សមត្ថភាពក្នុងការបង្កើតប្រតិបត្តិការផ្សេងទៀត ដែលអាចធ្វើឲ្យទំហំប្រាក់ចំណូល EBITDA និង FOCF របស់ខ្លួនកាន់តែប្រសើរឡើង ជាចំណុចសំខាន់ដែលត្រូវត្រួតពិនិត្យ និងតាមដានផងដែរ។

សេចក្តីសង្ខេបអំពីក្រុមហ៊ុន តែលកូថេក
ទិដ្ឋភាពទូទៅ

តែលកូថេក បានចាប់ផ្តើមនៅ ឆ្នាំ ២០០៧ ជាក្រុមហ៊ុនឯកជន ទទួលខុសត្រូវមានកម្រិត។ តែលកូថេកបានទទួលអាជ្ញាប័ណ្ណពី រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ("RGC") ដើម្បីដំណើរការ និងផ្តល់សេវាកម្ម បណ្តាញខ្សែកាប្ល៏ក្រោមបាតសមុទ្រ បណ្តាញខ្សែកាប្ល៏អុបទិក និងមជ្ឈមណ្ឌលទិន្នន័យ។ តែលកូថេក ត្រូវបានកាន់កាប់ដោយក្រុមហ៊ុន Ezecom Co., Ltd. ("Ezecom") ១០០% ដែលជាកម្មសិទ្ធិទាំងស្រុង របស់អ្នកឧកញ៉ា គិត ម៉េង។ បន្ទាប់ ពីការរៀបចំរចនាសម្ព័ន្ធឡើងវិញ នៅខែសីហា ឆ្នាំ ២០២១ តែលកូថេក ផ្តោតទៅលើអាជីវកម្មលក់ដុំ ខណៈពេលដែល Ezecom ផ្តោតលើអាជីវកម្មលក់រាយ។ នៅចុងឆ្នាំ២០២២ ប្រភពចំណូលចម្បង គឺ បានពីការជួលខ្សែបណ្តាញជាលក្ខណៈអន្តរជាតិដល់ក្រុមហ៊ុនឯកជន (International Private Lease Circuit: IPLC) ចំនួន ៣៨% នៃការលក់សរុប បន្ទាប់មកគឺ ការជួលខ្សែកាប្ល៏ក្នុងស្រុក(Domestic Lease Line) ចំនួន ២៦% និង ការលក់ដុំនៃខ្សែកាប្ល៏អុបទិក (Fiber Optic Wholesale) ចំនួន ១៨%។

តែលកូថេក គឺជាក្រុមហ៊ុននាំមុខគេមួយក្នុងចំណោមក្រុមហ៊ុនទាំង៣ ដែលក្នុងនោះ ២ទៀតជា ក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា("TC") និង ក្រុមហ៊ុន(ខេមបូឌា) ហ្វីប៊ើរ អុបទិច ខមញ្ញូនីខេសិនណេតវើក("CFOCN") ។ RAC មើលឃើញថាក្រុមហ៊ុនទាំងអស់ដែលកំពុងស្ថិតនៅក្នុងវិស័យឧស្សាហកម្មនេះ ជាដៃគូសហការ ច្រើនជាង ដៃគូប្រកួតប្រជែង ។ ឧទាហរណ៍ ប្រសិនបើ តំបន់មួយដែលក្រុមហ៊ុនមួយត្រូវបានអនុញ្ញាតដោយនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) ដើម្បីតម្លើងបណ្តាញខ្សែកាប្ល៏របស់ខ្លួន ក្រុមហ៊ុនផ្សេងទៀត មិនអាច រាយបណ្តាញខ្សែកាប្ល៏របស់ពួកគេនៅក្នុងតំបន់នោះបានទេ។ ដូចនេះ ប្រសិនបើ ក្រុមហ៊ុនទាំងនោះចង់ផ្តល់សេវាបណ្តាញខ្សែកាប្ល៏របស់ពួកគេ ដល់អតិថិជននៅក្នុងតំបន់នោះ ពួកគេ ត្រូវបានលើកទឹកចិត្តដោយ និយ័តករ ឲ្យធ្វើជាដៃគូ និងជួលបណ្តាញអុបទិកពីក្រុមហ៊ុនមួយនោះ។ លើសពីនេះទៀត គណៈគ្រប់គ្រង តែលកូថេក បានបញ្ជាក់ថា TC និង CFOCN គឺជា អ្នកផ្គត់ផ្គង់របស់ តែលកូថេកផងដែរ។ ទោះបីយ៉ាងនេះក៏ដោយ សម្រាប់គោលបំណងប្រៀបធៀប RAC ចាត់ទុក TC និង CFOCN ជាគូរប្រៀបធៀបដែលជិតបំផុតរបស់ តែលកូថេក ដោយសារតែក្រុមហ៊ុនដទៃទៀតដូចជា ក្រុមហ៊ុន អង្គរ ជាតា អ៊ិនហ្វ្រាស្ត្រាក់ឈ័រ ឯ.ក ("MekongNet") និងក្រុមហ៊ុន ម៉ាយក្រូម៉ាកស៍ ឯ.ក ("Micromax") នៅមានខ្នាតតូចនៅឡើយ។

ការប្រតិបត្តិ

គិតត្រឹមបំណាច់ឆ្នាំ ២០២២ ប្រាក់ចំណូលសរុប របស់ តែលកូថេក គឺ ប្រហែល ២២លានដុល្លារអាមេរិក ។ បន្ទាប់ពីការរៀបចំរចនាសម្ព័ន្ធឡើងវិញ នៅឆ្នាំ ២០២១ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបាន បង្ហាញឡើងវិញ ដើម្បីកាត់ផ្តាច់ផលប៉ះពាល់នៃប្រតិបត្តិការដែលបានបញ្ឈប់។ ដើម្បីអោយមានការប្រៀបធៀបពេញលេញទៅនឹងរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ យើងនឹងប្រើ របាយការណ៍ហិរញ្ញវត្ថុ រយៈពេលបីឆ្នាំកន្លងទៅនេះ។

តែលកូថេក ទទួលបានអត្ថប្រយោជន៍ពីការក្លាយជាក្រុមហ៊ុននាំមុខគេមួយក្នុងវិស័យឧស្សាហកម្មនេះ ដែលអាចឱ្យក្រុមហ៊ុនបង្កើតនូវកំណើនជាលំដាប់នៃប្រាក់ចំណូល និង EBITDA ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ។ EBITDA បានកើនឡើង ៣៥.១% CAGR ពី FY២០-FY២២ ដែលបង្ហាញពីការមាន គុណសម្បត្តិប្រកួតប្រជែង សមរម្យ របស់តែលកូថេក នៅក្នុងឧស្សាហកម្មនេះ។ លទ្ធផលនៃការរៀបចំរចនាសម្ព័ន្ធអាជីវកម្មនៅឡើងវិញនៅឆ្នាំ ២០២១ ដើម្បីផ្តោតលើការលក់ដុំ ហាក់ដូចជាអំណោយផលជាមួយនឹងការកើនឡើងនៃប្រាក់ចំណូល ៣៣.០% yoy និង EBITDA ដោយ ១៣៩.០% yoy នៅក្នុង FY២២ ។ ទោះជាយ៉ាងណាក៏ដោយ នេះគ្រាន់តែជាកំណត់ត្រាដែលមានភាពពេញលេញ ក្នុងមួយឆ្នាំប៉ុណ្ណោះ ដូចនេះយើងត្រូវបន្តតាមដាន ដើម្បីកំណត់បាននូវនិរន្តរភាពនៃគំរូអាជីវកម្មនេះ។ ចាប់ពី FY២០-FY២២ តែលកូថេក បានបង្ហាញពីសមត្ថភាពកាត់បន្ថយការចំណាយរបស់ខ្លួនជាបន្តបន្ទាប់ជាមួយនឹង ចំណាយប្រតិបត្តិការ និងរដ្ឋបាល (Operating and Administrative Expenses) ធ្លាក់ចុះ ២៣.២% p.a. ដែលភាគច្រើនបានមកពីការកាត់បន្ថយការចំណាយលើបុគ្គលិក (Personnel Expenses) ៤៣.៨% p.a.។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រាក់ចំណេញរបស់ក្រុមហ៊ុនពីប្រតិបត្តិការ (Profit from Operations) គឺអវិជ្ជមាននៅក្នុង FY២០ និង FY២១ ដោយសារតែកំណើនយឺតនៃប្រាក់ចំណូល។

តែលកូថេក បានរក្សាតារាងតុល្យការដែលមានសន្ទនីយភាពទាប ដោយ សមាមាត្របច្ចុប្បន្ន (Current Ratio: CR) ក្រោម ១x លើកលែងតែក្នុង FY២១ និង FY២២ នៅពេលដែល CR គឺ ១.៧x និង ១x រៀងគ្នា។ នេះភាគច្រើនដោយសារតែការថយចុះនៃ គណនីត្រូវទូទាត់អោយ (Trade and Other Payables) និង ប្រាក់ដែលត្រូវបង់ទៅ MPTC (Amounts due to MPTC) ដោយ ៥៤.០% yoy និង ៨៣.៥% yoy រៀងគ្នានៅក្នុង FY២១ ។ យ៉ាងណាមិញ គណនីទាំងពីរនេះបានកើនឡើងនៅក្នុង FY២២ ដែលធ្វើឱ្យ CR ធ្លាក់ចុះពី ១.៧x ក្នុងឆ្នាំ FY២១ ទៅ ១ x ក្នុងឆ្នាំ FY២២ ។ ការកើនឡើងនៃសាច់ប្រាក់ និងសមតុល្យធនាគារ (Cash and Bank Balances) និងប្រាក់បញ្ញើមានកាលកំណត់ (Term Deposits) នៅក្នុង FY២១ និង FY២២ គឺជាលទ្ធផលដែល ក្រុមហ៊ុនCGIF បានតម្រូវឲ្យ តែលកូថេក ប្រមូលគណនីត្រូវទទួល (Receivables from) ពីក្រុមហ៊ុន CAMGSM Plc. (“Cellcard”) ទាំងអស់មកវិញ ដែលមានបរិមាណសរុបចំនួន ១៥ លានដុល្លារអាមេរិក ហើយត្រូវបានទូទាត់អស់នៅក្នុងខែមិថុនា ឆ្នាំ ២០២៣ - ដែលជាផ្នែកមួយនៃតម្រូវការនៃការធានាទៅលើឥណទានសញ្ញាបណ្ណជំបូងចំនួន ២០ លានដុល្លារក្នុងឆ្នាំ ២០២១ ។ ក្រុមហ៊ុនបានស្វែងរកហិរញ្ញប្បទានសម្រាប់ CAPEX របស់ខ្លួនតាមរយៈឥណទានសញ្ញាបណ្ណដែលត្រូវបានធានាលើកជំបូងក្នុងឆ្នាំ ២០២១។ ទោះបីជាមានការបំពានលើកិច្ចព្រមព្រៀងនៃឥណទានសញ្ញាបណ្ណនេះទាក់ទងនឹង CR ក្នុងឆ្នាំ ២០២២ ក៏ដោយ អ្នកឱ្យខ្ចីបានលើកលែងនូវការបំពាននេះ ដូច្នេះ មូលបត្របំណុល (Debt Securities) នៅតែបន្តបង្ហាញជា រយៈពេលវែង(non-current)។

ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនត្រូវបន្តការវិនិយោគលើ CAPEX ដើម្បីរក្សាជំហរប្រកួតប្រជែងរបស់ខ្លួន។ នេះបានពង្រីកទំហំបំណុលរបស់ក្រុមហ៊ុន ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ (FY២១-FY២២)។ បន្ទាប់ពីការបោះផ្សាយឥណទានសញ្ញាបណ្ណលើកជំបូងចំនួន ២០ លានដុល្លារអាមេរិក អនុបាតបំណុលធៀបនឹងដើមទុន (Debt/Capital) របស់ក្រុមហ៊ុនបានកើនឡើងពី ២៨.១% ក្នុង FY២០ ទៅ ៤៩.៩% ក្នុង FY២១ និង ៤៩.៨% ក្នុង FY២២ ។ ជាចុងក្រោយ EBITDA និង FOCF បានកើនឡើង ១៣៩.០% yoy និង ១៩៧.៩% yoy រៀងគ្នានៅក្នុង FY២២។ ទោះបីជាយ៉ាងនេះក៏ដោយ លំហូរសាច់ប្រាក់ទំនេរ (FOCF) ចំនួន ៦,៩៥៣,០៧៣ ដុល្លារអាមេរិក នៅក្នុង FY២២ មិនមានទំហំគ្រប់គ្រាន់ដើម្បីគាំទ្របន្ថែមនូវហិរញ្ញប្បទាន

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៣
#២៤៦, មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកក់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
www.ratingagencyofcambodia.com.kh | (+៨៥៥)២៣ ៩០២ ៤០៨ | info@ratingagencyofcambodia.com.kh

	ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២		ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១		ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០	
	៣ន់រៀ ល	ដុល្លារអាមេរិក	៣ន់រៀ ល	ដុល្លារអាមេរិក	៣ន់រៀ ល	ដុល្លារអាមេរិក
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ						
ទ្រព្យសកម្ម						
សាច់ប្រាក់ និងសមតុល្យធនាគារ	45,071,368	10,947,624	14,487,071	3,555,982	3,176,676	785,334
ទ្រព្យសកម្មរយៈពេលខ្លីសរុប	**85,318,394**	**20,723,438**	**94,740,130**	**23,254,818**	**101,768,224**	**25,159,017**
ទ្រព្យសម្បត្តិ និង គ្រឿងបរិក្ខារ	165,894,828	40,295,076	138,002,016	33,873,838	155,013,655	38,322,288
ទ្រព្យសកម្មរយៈពេលវែងសរុប	**186,478,395**	**45,294,728**	**156,895,749**	**38,511,475**	**155,013,655**	**38,322,288**
ទ្រព្យសកម្មសរុប	**271,796,789**	**66,018,166**	**251,635,879**	**61,766,293**	**256,781,879**	**63,481,305**
បំណុល						
បំណុល និង កម្ចី	16,568,319	4,024,367	16,588,098	4,071,698	11,421,531	2,823,617
បំណុលរយៈពេលខ្លីសរុប	**82,495,610**	**20,037,797**	**55,891,793**	**13,719,144**	**112,139,795**	**27,723,064**
បំណុល និងកម្ចី	47,180,487	11,459,919	62,196,821	15,266,770	18,724,434	4,629,032
បំណុលរយៈពេលវែងសរុប	**61,255,966**	**14,878,787**	**77,382,135**	**18,994,142**	**25,400,569**	**6,279,498**
បំណុលសរុប	**143,751,576**	**34,916,584**	**133,273,928**	**32,713,286**	**137,540,364**	**34,002,562**
មូលធន						
ដើមទុន	48,019,586	11,856,688	48,019,586	11,856,688	48,019,586	11,856,688
បុព្វលាភភាគហ៊ុន	78,042,579	19,244,894	69,670,053	17,196,319	71,401,949	17,622,055
មូលធនសរុប	**128,045,213**	**31,101,582**	**118,361,951**	**29,053,007**	**119,241,515**	**29,478,743**
បំណុលនិងមូលធនសរុប	**271,796,789**	**66,018,166**	**251,635,879**	**61,766,293**	**256,781,879**	**63,481,305**

	ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២		ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១		ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០	
	៣ន់រៀ ល	ដុល្លារអាមេរិក	៣ន់រៀ ល	ដុល្លារអាមេរិក	៣ន់រៀ ល	ដុល្លារអាមេរិក
របាយការណ៍លំហូរសាច់ប្រាក់						
សាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការ	46,632,728	11,410,014	47,355,610	11,641,006	28,063,980	6,883,488
សាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ	3,191,280	780,837	(62,182,980)	(15,285,885)	(16,787,968)	(4,117,726)
សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញប្បទាន	(16,712,597)	(4,089,209)	28,735,857	7,063,878	(12,693,087)	(3,113,340)
(តំហយ)/កំណើន សាច់ប្រាក់ និងសាច់ប្រាក់ សមមូលសុទ្ធ	**33,111,411**	**8,101,642**	**13,908,487**	**3,418,999**	**(1,417,075)**	**(347,578)**

	ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២		ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១		ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០	
	៣ន់រៀ ល	ដុល្លារអាមេរិក	៣ន់រៀ ល	ដុល្លារអាមេរិក	៣ន់រៀ ល	ដុល្លារអាមេរិក
របាយការណ៍ចំណេញ/ខាត						
ចំណូល	89,685,046	21,943,980	67,142,836	16,505,122	66,124,961	16,219,024
ចំណេញដុល	18,864,488	4,615,730	5,308,923	1,305,045	3,991,652	979,066
ប្រាក់ចំណេញពីប្រតិបត្តិការ	15,428,098	3,774,920	(1,148,418)	(282,305)	(3,585,439)	(879,431)
ចំណេញមុនពេលបង់ពន្ធ	10,481,169	2,564,514	(7,138,784)	(1,754,863)	(7,727,687)	(1,895,435)
ចំណេញក្រោយពេលបង់ពន្ធ	8,372,526	2,048,575	(7,339,837)	(1,804,286)	(8,660,570)	(2,124,251)
លទ្ធិផលលម្អិតក្នុងការិយបរិច្ឆេទ	**9,683,262**	**2,048,575**	**(879,564)**	**(425,736)**	**(4,436,206)**	**(871,618)**

និយមន័យចំណាត់ថ្នាក់ឥណទាន

ចំណាត់ថ្នាក់វាយតម្លៃឥណទាន(ចំណាត់ថ្នាក់ជាតិ)			
ចំណាត់ថ្នាក់ជាតិ	**និយមន័យ**		
khAAA	សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	១	ហានិភ័យទាបណាស់
khAA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	២	
khA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាល:ទេស: និងបរិយាកាសសេដ្ឋកិច្ច	៣	ហានិភ័យទាប
khBBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែមានភាពងាយនឹងទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាល:ទេស: និងបរិយាកាសសេដ្ឋកិច្ច	៤	
khBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងគ្រោះជាងទៅតាមការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាល:ទេស: និងបរិយាកាសសេដ្ឋកិច្ច	៥	ហានិភ័យមធ្យម
khB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាល:ទេស: និងបរិយាកាសសេដ្ឋកិច្ច	៦	
khCCC	សមត្ថភាពបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ អាស្រ័យលើលក្ខខណ្ឌអាជីវកម្ម ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចអំណោយផល	៧	ហានិភ័យខ្ពស់
khCC	សមត្ថភាពខ្សោយក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៨	
khC	ទំនងជាមិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៩	ហានិភ័យខ្ពស់ណាស់
khD	មិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ មួយផ្នែក ឬ ទាំងអស់	១០	

សេចក្តីថ្លែងមិនទទួលខុសត្រូវ

ព័ត៌មាន និងទិន្នន័យស្ថិតនៅទីនេះត្រូវបានទទួលពីប្រភពដែលយើងជឿថាអាចទុកចិត្តបាន។ ព័ត៌មានបែបនេះមិនត្រូវបានផ្ទៀងផ្ទាត់ដោយឯករាជ្យទេ ហើយយើងមិនតំណាង ឬការធានាចំពោះភាពត្រឹមត្រូវច្បាស់លាស់ និងភាពពេញលេញរបស់ព័ត៌មានឡើយ។ រាល់មតិ ឬការប៉ាន់ប្រមាណនៅទីនេះឆ្លុះបញ្ចាំងពីការវិនិច្ឆ័យរបស់ក្រុមហ៊ុន រេតជីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក (ដែលហៅកាត់ថា "RAC") នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយអាចផ្លាស់ប្តូរបានគ្រប់ពេលដោយមិនមានការជូនដំណឹងជាមុន។ រាល់ការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យនៅទីនេះ បង្កើតជាការវិនិច្ឆ័យគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយមិនអាចមានការធានាថា លទ្ធផល ឬព្រឹត្តិការណ៍នាពេលអនាគតនឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យណាមួយឡើយ។ ព័ត៌មាននៅក្នុងឯកសារនេះគឺអាចផ្លាស់ប្តូរដោយគ្មានការជូនដំណឹង ភាពត្រឹមត្រូវច្បាស់លាស់របស់វាមិនត្រូវបានធានាទេ វាអាចមិនពេញលេញ ឬបង្រួម ហើយវាប្រហែលជាមិនមែនព័ត៌មានធំ ទាំងអស់ទាក់ទងនឹងក្រុមហ៊ុន (ឬក្រុមហ៊ុនច្រើន) ដែលយោងទៅតាមរបាយការណ៍នេះទេ ហើយ RAC មិនស្ថិតនៅក្រោមភាពតព្វកិច្ច ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍នេះផងដែរ។ ក្នុងវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ RAC និងនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ខ្លួនមិនទទួលខុសត្រូវចំពោះការខូចខាត ដោយផ្ទាល់ ឬសំណងណាមួយចំពោះបុគ្គល ឬអង្គភាពណាមួយ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ដោយការធ្វេសប្រហែសណាមួយនៅក្នុងផ្នែកនៃ ឬបញ្ហាអាសន្នណាមួយនៅក្នុង ឬលើសពីការគ្រប់គ្រងរបស់ RAC ឬនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់ខ្លួន ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងព័ត៌មានដែលមាននៅទីនេះ ឬ ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានបែបនេះ។